# សុន្ទរកថា
# ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងពិធីបើកសន្និបាតបូកសរុបការងារឆ្នាំ ២០១៨
# និងទិសដៅការងារឆ្នាំ ២០១៩
# របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ថ្ងៃទី៥ ដល់ ៧ ខែមីនា ឆ្នាំ២០១៩

---------------------------

ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយស
ឯកឧត្តម លោកជំទាវ លោក លោកស្រី
អង្គសន្និបាតទាំងមូលជាទីមេត្រី!

ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះវត្តមានដ៏ថ្លៃថ្លារបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងសន្និបាតប្រចាំឆ្នាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នាព្រឹកនេះ។

អំបាញ់មិញ យើងបានស្តាប់នូវរបាយការណ៍បូកសរុបការងារឆ្នាំ២០១៨ របស់ក្រសួងដែលអានដោយ ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ  អ៊ុច បូរិទ្ធ។ របាយការណ៍នេះ បានរំលេចសមិទ្ធផលការងារជាច្រើនដែលក្រសួងសម្រេចបាន ក្នុងការអនុវត្តនយោបាយការបរទេសរបស់រាជរដ្ឋា  ភិបាល សំដៅការពារនិងលើកស្ទួយផលប្រយោជន៍ជាតិ លើកកំពស់កិត្តិនាមព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ និងរួមចំណែកការពារឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីប្រទេសជាតិ។

បន្ទាប់ពីការបើកសន្និបាត យើងនឹងស្តាប់ការធ្វើបទបង្ហាញរបស់ ឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ  ស្តីពី«យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា» និង «វិធានការនានាដើម្បីទប់ទល់នឹងយថាភាពនៃការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធក្នុងក្របខ័ណ្ឌគ្រប់មុខទំនិញទាំងអស់លើកលែងសព្វាវុធ» និងបទបង្ហាញរបស់ឯកឧត្តម **ទឹន ពន្លក** អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពស្តីពី «ជំហររបស់កម្ពុជាចំពោះបញ្ហាការប្រែប្រួលអាកាសធាតុ»។ ចាប់ពីរសៀលថ្ងៃទី ៥ រហូតដល់ថ្ងៃទី ៦ ខែមីនា យើងនឹងមានកិច្ចប្រជុំចង្អៀត ដែលក្នុងនោះ យើងនឹងមានការពិភាក្សាដោយមានការបែងចែកជាក្រុម ដើម្បីផ្តល់លទ្ធភាពឲ្យមានការផ្លាស់ប្តូរមតិយោបល់ឲ្យកាន់តែច្រើន និងស៊ីជម្រៅជាងឆ្នាំមុនៗ ទាំងលើផ្នែកខ្លឹមសារការងារ និងទិសដៅយុទ្ធសាស្ត្រ។ ក្នុងឱកាសនោះដែរ យើងក៏នឹងស្តាប់ការធ្វើបទបង្ហាញរបស់ឯកឧត្តម  **ញឹម ខេមរា** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលនឹងបង្ហាញអំពីទស្សនៈស្តីពី «ការជំរុញការទូតសេដ្ឋកិច្ច ទេសចរណ៍ និងវប្បធម៌» ផងដែរ ។

នៅព្រឹកថ្ងៃទី៧ ខែមីនា នាឱកាសបិទសន្និបាត យើងនឹងមានមហាកិត្តិយសទទួលស្វាគមន៍ និងត្រងត្រាប់ស្តាប់នូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់ និងចក្ខុវិស័យប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**

ក្នុងការតម្រែតម្រង់ និងកំណត់ទិសដៅនៃគោលនយោបាយការបរទេស សំដៅសម្រេចឲ្យបាននូវជ័យជំនះថ្មីៗថែមទៀត នូវការងារការទូតរបស់យើង។

ខ្ញុំសង្ឃឹមថា សន្និបាតរយៈពេលពីរថ្ងៃកន្លះនេះ នឹងផ្តល់ឱកាសគ្រប់គ្រាន់ ដើម្បីឲ្យយើងបានពិនិត្យពិភាក្សា និងវាយតម្លៃពីលទ្ធផលការងារដែលសំរេចបាន ក៏ដូចជាធ្វើការវាយតម្លៃសភាពការណ៍តំបន់ និងពិភពលោក ព្រមទាំងកំណត់បញ្ហាប្រឈម និងទិសដៅអនាគត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ឆ្នាំ ២០១៩ និងបណ្តាឆ្នាំតទៅមុខ ស្ថានការណ៍ពិភពលោកនឹងបន្តប្រែប្រួលយ៉ាងជ្រាលជ្រៅ ស្មុគស្មាញ ឆាប់រហ័ស និងពិបាកប៉ាន់ស្មានបាន។

ដំណើរប្រែប្រួលទៅកាន់ប្រព័ន្ធពហុប៉ូលនៅបន្តទៅមុខ។ ទោះបីមានការប្រឆាំងទប់ទល់ ដើម្បីរក្សាឧត្តមភាពទោលនៅលើលោក តាមគ្រប់រូបភាពយ៉ាងណាក៏ដោយ ក៏ការងើបឡើងកាន់តែជាក់ច្បាស់របស់តួអង្គផ្សេងទៀត នឹងទាញការទទួលខុសត្រូវក្នុងការចាត់ចែងកិច្ចការពិភពលោកទៅរកប៉ូលថ្មី បង្កើតជាការប្រកួតប្រជែងជាយុទ្ធសាស្ត្រ ដើម្បីអំណាច ឥទ្ធិពល និងផលប្រយោជន៍។

ទំនាក់ទំនងរវាងមហាអំណាចទី ១ និងមហាអំណាចទី ២ ទោះក្នុងរូបភាព និងលក្ខណៈណាក៏ដោយ នឹងជះឥទ្ធិពលលើដំណើររបស់ពិភពលោកទាំងមូល ទាំងខាងនយោបាយ សន្តិសុខ សេដ្ឋកិច្ច និងបច្ចេកវិទ្យា។

ការងាកចេញរបស់មហាអំណាចទី ១ ពីប្រព័ន្ធពហុភាគីនិយម ទៅកាន់ឯកតោភាគីនិយម និងគាំពារនិយម កំពុងគំរាមដល់ប្រព័ន្ធសណ្តាប់ធ្នាប់ពិភពលោកបច្ចុប្បន្ន ដែលជាវិធានសម្រាប់ចាត់ចែងទំនាក់ទំនងអន្តរជាតិ អស់កាលជាង៧០ឆ្នាំមកហើយ។

ភ្នក់ជម្លោះតាមតំបន់នានា នៅមជ្ឈិមបូព៌ា អឺរ៉ុបខាងកើត អាហ្វ្រិក អាមេរិកឡាទីន និងនៅអាស៊ី បញ្ហាប្រឈមធ្ងន់ធ្ងរ តួយ៉ាង អំពើភេរវកម្ម វិបត្តិជនភៀសខ្លួន ឧក្រិដ្ឋកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យា ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរមនុស្ស / គ្រឿងញៀន ការប្រែប្រួលធាតុអាកាស និងបញ្ហា បរិស្ថាន ជំងឺឆ្លង និងគ្រោះធម្មជាតិ។ល។ នឹងនៅតែបន្តគំរាមកំហែងដល់សន្តិសុខពិភពលោក និងត្រូវការការរួមកម្លាំងទាំងអស់គ្នាដើម្បីឆ្លើយតបដោះស្រាយ។

ដូចដែលឯកឧត្តមរដ្ឋលេខាធិការ **អ៊ុច បូរិទ្ធ** បានលើកឡើងមុននេះ តំបន់អាស៊ី-ប៉ាស៊ីហ្វិក នឹងនៅតែជាចំណុចកណ្តាលនៃការប្រកួតប្រជែងរបស់មហាអំណាចធំៗ។ ការងើបឡើងរបស់បណ្តាប្រទេសនៅអាស៊ីនាំមុខដោយ ចិន ជប៉ុន ឥណ្ឌា កូរ៉េខាងត្បូង និងអាស៊ាន កំពុងធ្វើឲ្យជញ្ជីងអំណាចផ្អៀងពីភាគខាងលិចមកភាគខាងកើត។

អាស៊ាននឹងបន្តជាគម្រូនៃសមាហរណកម្មប្រកបដោយជោគជ័យផង ជាកម្មវត្ថុនៃការចង់ភ្ជាប់ភាពជាដៃគូជាមួយផង និងក៏ជាកន្លែងដែលទទួលរងឥទ្ធិពល និងសម្ពាធពីការប្រកួតប្រជែងនោះផង។

ការប្រកួតគ្នារវាងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវរបស់ចិន និងយុទ្ធ សាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិកសេរី និងបើកចំហដែលកំពុងលេចចេញជារូបរាងរបស់អាមេរិក និងសម្ព័ន្ធមិត្តក្នុងតំបន់ បញ្ហាសមុទ្រចិនខាងត្បូង បញ្ហាឧបទ្វីបកូរ៉េ និងបញ្ហាជាច្រើនទៀត នឹងធ្វើឲ្យអាស៊ី-ប៉ាស៊ីហ្វិក បន្តនៅជាតំបន់ដ៏ក្តៅ រំជើបរំជួល ប្រែប្រួលឆាប់រហ័ស។

គឺក្នុងបរិបទនេះហើយដែលសន្និបាតរបស់យើងត្រូវរួមគ្នាពិនិត្យ ពិភាក្សា ផ្លាស់ប្តូរយោបល់ ដើម្បីស្វែងយល់ពីយថាភាពនៃការវិវត្តទៅមុខនៃសភាពការណ៍តំបន់ និងពិភពលោក ផលប៉ះពាល់ទាំងឡាយមកលើតំបន់ និងកម្ពុជាផ្ទាល់។ នៅទីនេះ មានថ្នាក់ដឹកនាំ អ្នកការទូតដ៏មានបទពិសោធន៍ មានថ្នាក់ដឹកនាំ និងមន្ត្រីវ័យក្មេងប្រកបដោយសមត្ថភាព មានអ្នកស្រាវជ្រាវ វិភាគជាច្រើន.... ហេតុនេះ ខ្ញុំសង្ឃឹមថា យើងនឹងអាចប្រមូលធាតុចូល គំនិតយោបល់ និងការពិចារណាលើយុទ្ធសាស្ត្រ សកម្មភាព វិធានការការទូតនានា ដើម្បីបន្តការពារផលប្រយោជន៍របស់ប្រទេសជាតិយើង។

ក្នុងឱកាសបើកសន្និបាតរបស់ក្រសួងកាលពីឆ្នាំទៅមិញ ខ្ញុំបានដាក់ចេញនូវការងារធំៗ ៥ សម្រាប់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិអនុវត្ត។

ឯកឧត្តម **អ៊ុច បូរិទ្ធ** បានរៀបរាប់រួចហើយនូវការងារទាំង ៥ នោះ ក៏ដូចជាសមិទ្ធផលដែលយើងសម្រេចបានក្នុងឆ្នាំកន្លងទៅ។

ឥឡូវនេះ ខ្ញុំសូមផ្តល់ជូននូវគំនិតដាក់ស្តែងមួយចំនួន ដើម្បីអង្គសន្និបាតរបស់យើង យកធ្វើជាមូលដ្ឋានសម្រាប់ការពិភាក្សា ដូចតទៅ៖

- សំណួរទី ១ ដែលយើងគួរពិចារណាឆ្លើយតបគឺថា តើការងារទាំង ៥ នេះត្រឹមត្រូវ និងគ្រប់គ្រាន់ហើយឬនៅ សម្រាប់អនុវត្តឲ្យបានជោគជ័យនូវនយោបាយការបរទេសរបស់កម្ពុជា?
- ពាក្យថា ត្រឹមត្រូវគឺចង់សំដៅថា តើការងារទាំង ៥ នោះបានឆ្លើយតបចំពេល ចំបញ្ហា និងការពារបានផលប្រយោជន៍គោលរបស់ប្រទេសជាតិ និងប្រជាជនយើងដែរឬទេ ក្នុងស្ថានភាពដែលកម្ពុជាយើង ក៏ដូចជាប្រទេសតូចធំនានា ក្នុងតំបន់ និងពិភពលោក កំពុងទទួលរងផលប៉ះពាល់ពីឥទ្ធិពល និងសម្ពាធ ដែលកើតចេញពីការប្រកួតប្រជែងកាន់តែតានតឹងឡើងរបស់មហាអំណាចធំៗនោះ?
- តើយុទ្ធសាស្ត្រ យុទ្ធវិធី សកម្មភាព និងវិធានការនានាដែលរាជ រដ្ឋាភិបាលកម្ពុជាបានអនុម័ត និងប្រកាន់យក សមស្របដែរឬទេ?
- ពាក្យថា គ្រប់គ្រាន់សំដៅលើប្រការដែលថា តើការងារ ៥យ៉ាងនេះ គ្រប់ជ្រុងជ្រោយហើយឬនៅ? តើមានការងារណាផ្សេងទៀតដែលត្រូវបញ្ចូល និងយកចិត្តទុកដាក់បន្ថែមដែរឬទេ?
- តើយើងជួបការលំបាក ការប្រឈមយ៉ាងម៉េចខ្លះ ក្នុងការអនុវត្តការងារទាំង ៥ នេះ កន្លងមក? មានគំនិត និងដំណោះស្រាយយ៉ាងដូចម្តេចខ្លះ ចំពោះការប្រឈមនោះ?

- តើការប្រឈមតទៅមុខ នឹងអាចមានអ្វីខ្លះ?
- តើត្រូវធ្វើម៉េចទប់ទល់ឆ្លើយតបនឹងការអនុវត្តស្តង់ដារពីរ មកលើយើង ការពារយុត្តិធម៌សម្រាប់កម្ពុជា សម្រាប់រាជរដ្ឋាភិបាល សម្រាប់ប្រជាជនយើង? ការពារឯករាជ្យ អធិបតេយ្យជាតិ?

កន្លងទៅ យើងបានកំណត់រួចហើយនូវជំហរជាគោលការណ៍របស់រាជ រដ្ឋាភិបាលកម្ពុជា ចំពោះបញ្ហានានានៅក្នុងតំបន់ និងពិភពលោក។ យើងនឹងបន្តតាមដានការវិវត្តប្រែប្រួលនៃបញ្ហាទាំងនោះ ដើម្បីសម្រប ឬបត់បែនជំហររបស់យើង ស្របតាមស្ថានការណ៍ជាក់ស្តែង។

ចំពោះការងារទី ៥ ដែលទាក់ទងនឹងកំណែទម្រង់ផ្ទៃក្នុងរបស់ក្រសួង យើងនឹងពិភាក្សាអំពីវិធានការទាំងឡាយ ដើម្បីបង្កើនថែមទៀតនូវប្រសិទ្ធភាពការងារ និងរក្សាបរិស្ថានសមធម៌ ក្នុងក្រសួងតទៅទៀត។ សម្រាប់មន្ត្រីការទូតរបស់យើង ដែលបំពេញការងារនៅក្រៅប្រទេស បញ្ហាដ៏សំខាន់មួយដែលជាក្តីបារម្ភរបស់មន្ត្រីទាំងនោះ គឺបញ្ហាសុខភាព និងចំណាយសំរាប់ការព្យាបាលក្នុងពេលធ្លាក់ខ្លួនឈឺ ឬមានគ្រោះថ្នាក់។ ដោយហេតុនេះ ការគិតគូរដល់ការទិញធានារ៉ាប់រងផ្នែកសុខភាព នឹងត្រូវ យកមកពិចារណា។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ សូមប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសូមឱ្យអង្គសន្និបាតទាំងមូលប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ និងទទួលបានលទ្ធផលជាផ្លែផ្កា។

ខ្ញុំសូមប្រកាសបើក «សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ» ចាប់ពីពេលនេះតទៅ។

សូមអរគុណ!